Updated 28/02/2001

" **សេចក្តីព្រាងច្បាប់** "

# ច្បាប់

**ស្តីពី**

# សមាគម និងអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ :** ច្បាប់នេះមានគោលដៅកំណត់បែបបទ លក្ខខ័ណ្ឌនៃការបង្កើត និងការចុះបញ្ជីរបស់សមាគម និងអង្គការក្រៅរដ្ឋាភិបាល ។

**មាត្រា ២ :** ច្បាប់នេះមិនអនុវត្តចំពោះ :

-គណបក្សនយោបាយ

-អង្គការដែលមានគោលដៅរកកំរៃ ឧស្សាហកម្ម ពាណិជ្ជកម្ម ឬ សេវាកម្ម

-សមាគមនិយោជក

-សហជីព

-អង្គការក្រៅរដ្ឋាភិបាលបរទេស ។

**មាត្រា ៣ :** ១. សមាគម គឺជាក្រុមរូបវន្តបុគ្គល ដែលរៀបចំឡើងដោយជនជាតិខ្មែរ ដើម្បីគិតគូរពីវត្ថុបំណងរួម សំដៅបំរើផលប្រយោជន៍ ទាំងខាងស្មារតី ទាំងខាងសំភារៈរបស់សមាជិក សមាគមដោយមិនស្វែងរកផលចំណេញជាឯកជន ។

២. អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក គឺជាក្រុមរូបវន្តបុគ្គល ដែលរៀបចំឡើងដោយ ប្រជាពលរដ្ឋខ្មែរ សំដៅបំរើផលប្រយោជន៍សាធារណៈដោយមិនធ្វើអាជីវកម្មរកផលចំណេញឯកជន ។

**មាត្រា ៤ :** សមាគម និងអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក ត្រូវមានទីស្នាក់ការអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ៥ :** ការចុះបញ្ជីរបស់សមាគម និងអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក ជាសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃ ។

Updated 28/02/2001

## ជំពូកទី ២
## ការបង្កើត និង ការគ្រប់គ្រងសមាគម

**មាត្រា ៦ :** ដើម្បីឱ្យសមាគមទទួលបាននូវបុគ្គលភាពគតិយុត្តិ ជានីតិបុគ្គល ស្ថាបនិកត្រូវដាក់ ឬ ផ្ញើពាក្យ សុំចុះបញ្ជីជូនក្រសួងមហាផ្ទៃ ដោយភ្ជាប់ជាមួយនូវសំណុំលិខិតដូចខាងក្រោម :

១. ប្រវត្តិរូបនៃសមាជិកស្ថាបនិកយ៉ាងតិច៣រូប អាយុលើសពី១៨ឆ្នាំ របស់សមាគម ក្នុងមួយនាក់ពីរច្បាប់ ដោយមានបិទរូបថតទំហំ ៤ គុណនឹង ៦

២. ឈ្មោះជាអក្សរពេញ អក្សរកាត់ ជាអក្សរខ្មែរ និងអក្សរឡាតាំង និងសញ្ញាសំគាល់ របស់សមាគម ប្រសិនបើមាន

៣. អាស័យដ្ឋាននៃទីស្នាក់កណ្តាលរបស់សមាគម

៤. ច្បាប់ដើមលក្ខន្តិកៈរបស់សមាគម ០២ ច្បាប់

៥. បទបញ្ជាផ្ទៃក្នុងរបស់សមាគម ប្រសិនបើមាន ។

**មាត្រា ៧ :** ក្រសួងមហាផ្ទៃ ត្រូវផ្តល់បង្កាន់ដៃទទួលពាក្យសុំមួយច្បាប់ ជូនដល់ស្ថាបនិករបស់សមាគមណាដែល បានផ្តល់សំណុំលិខិត គ្រប់គ្រាន់តាមការកំណត់ដូចមានចែងក្នុងមាត្រា ៦ នៃច្បាប់នេះ ដើម្បីសុំចុះ បញ្ជី ។

**មាត្រា ៨ :** ក្រសួងមហាផ្ទៃ ត្រូវឆ្លើយតបជាលាយលក្ខណ៍អក្សរចំពោះ ស្ថាបនិករបស់សមាគមវិញ ក្នុងរយៈពេល **៩៥** ថ្ងៃ បន្ទាប់ពីថ្ងៃទទួលសំណុំលិខិតសុំចុះបញ្ជី ។ ការឆ្លើយតបនេះត្រូវ មានសេចក្តីបញ្ជាក់ណាមួយ ដូចខាងក្រោម :

-សមាគម ត្រូវបានយល់ព្រមឱ្យចុះបញ្ជីត្រឹមត្រូវតាមផ្លូវច្បាប់

-សមាគម ត្រូវកែសំរួល ឬ បំពេញបន្ថែមលើសំណុំលិខិត

-សមាគម ត្រូវបានបដិសេធនូវការចុះបញ្ជី ។

ប្រសិនបើក្រសួងមហាផ្ទៃ មិនបានឆ្លើយតបជាលាយលក្ខណ៍អក្សរ ក្នុងរយៈពេល **៩៥** ថ្ងៃ បន្ទាប់ពីថ្ងៃទទួលសំណុំលិខិតសុំចុះបញ្ជីនោះទេ សមាគមត្រូវចាត់ទុកថាបានទទួលសុពលភាព តាមផ្លូវច្បាប់។

**មាត្រា ៩ :** ក្នុងករណីមានការកែសំរួល តម្រូវឱ្យ ឬបំពេញបន្ថែមលើសំណុំលិខិត ស្ថាបនិករបស់សមាគមត្រូវផ្តល់ ឬ បំពេញសំណុំលិខិតខ្វះខាតរបស់ខ្លួនក្នុងរយៈពេលយ៉ាងយូរ ៣០ថ្ងៃ បន្ទាប់ពីថ្ងៃទទួលលិខិតជូនដំណឹងរបស់ក្រសួងមហាផ្ទៃ។ បើហួសរយៈពេលកំណត់ ក្រសួងមហាផ្ទៃ ចាត់ទុកថា

ស្ថាបនិករបស់សមាគមនោះ បានបោះបង់ចោលគំរោងការរបស់ខ្លួន នឹងមិនត្រូវបានទទួលសុពលភាព ខាងផ្លូវច្បាប់ ដូចមានចែងក្នុងមាត្រា៩ នៃច្បាប់នេះ ។

**មាត្រា ១០ :** ប្រសិនបើសមាគមណាមួយ ត្រូវបានក្រសួងមហាផ្ទៃបដិសេធនូវការចុះបញ្ជីសមាគម អ្នកផ្តើមបង្កើតសមាគមនោះ អាចប្តឹងទៅតុលាការ ដើម្បីទាមទារឱ្យមានការចុះបញ្ជី ។

**មាត្រា ១១ :** សមាគមមួយត្រូវមានសមាជិកស្ថាបនិកយ៉ាងតិច ០៣ រូប ។ សមាជិកសមាគម គឺជាអ្នកដែលបានគាំទ្រ ឬ ផ្តល់ ឬ ចូលរួមបំរើសកម្មភាពរបស់សមាគម ។ សិទ្ធិ ភារកិច្ច និង នីតិវិធីនៃការជ្រើសរើស ឬ ការបញ្ឈប់សមាជិកត្រូវកំណត់ក្នុងលក្ខន្តិកៈ ។

**មាត្រា ១២ :** អង្គការដឹកនាំរបស់សមាគមនីមួយៗ ត្រូវមានយ៉ាងតិច : ប្រធាន ក្រុមប្រឹក្សាភិបាល ហិរញ្ញិក និង សន្និបាត ។ អាណត្តិ ភារកិច្ច និង នីតិវិធី នៃការជ្រើសតាំង ការដកហូត និង សិទ្ធិ សំរេចការងារនីមួយៗ ត្រូវកំណត់ក្នុងលក្ខន្តិកៈ ។

**មាត្រា ១៣ :** ប្រភពធនធានរបស់សមាគមរួមមាន :

-វិភាគទាន ភាគទានរបស់សមាជិក

-ចំណូលផ្សេងៗបានមកពីសកម្មភាពស្របច្បាប់

-វិភាគទានហិរញ្ញវត្ថុ ឬ អំណោយជាទេយ្យទាន ដែលផ្តល់ដោយបុគ្គល ឬ នីតិបុគ្គល

-អំណោយ និង អំណោយមរតកសាសន៍ពីបុគ្គលឯកជន ។

វិធាន និង នីតិវិធីនៃការចាត់ចែងគ្រប់គ្រងធនធានរបស់សមាគម ត្រូវកំណត់លក្ខន្តិកៈ ។

**មាត្រា ១៤ :** ក្រសួងមហាផ្ទៃពិនិត្យភាពស្របច្បាប់នៃលក្ខន្តិកៈរបស់សមាគម ដែលបានស្នើសុំចុះបញ្ជី។ លក្ខន្តិកៈត្រូវសរសេរជាភាសាខ្មែរ និង មានចំណុចសំខាន់ៗ យ៉ាងតិច ដូចតទៅ :

១. អត្តសញ្ញាណនៃសមាគមរួមមាន : ឈ្មោះ សញ្ញាសំគាល់ប្រសិនបើមាន អាស័យដ្ឋានទីស្នាក់ការកណ្តាល គោលបំណង និង ឧបនិស្ស័យ ។

២. អង្គការដឹកនាំសំខាន់ៗនៃសមាគមរួមមាន : ប្រធាន ក្រុមប្រឹក្សាភិបាល ហិរញ្ញិក និង សន្និបាត ។

៣. របបនៃការប្រជុំប្រចាំឆ្នាំរបស់សមាគមរួមមាន : ចំនួនលើកនៃកិច្ចប្រជុំប្រចាំឆ្នាំនៃអង្គការនានា ចំនួនកូរ៉ុមដើម្បីសំរេចការងារ វិធាននៃការបោះឆ្នោត និង សំលេងភាគច្រើនដែលទទួលយកជាករណីទូទៅ ឬ ក្នុងករណីពិសេស ។

៤. វិធាន និង នីតិវិធីនៃការចាត់ចែង គ្រប់គ្រងធនធាន ។

៥. វិធាននៃការកែប្រែលក្ខន្តិកៈ ការរំលាយ ការធ្វើសម្ព័ន្ធភាព និង ការផ្ទេរទ្រព្យសម្បត្តិនៅពេលសមាគមត្រូវរំលាយ ។

៦. លក្ខន្តិកៈរបស់សមាគម ត្រូវចុះហត្ថលេខាដោយតំណាងស្ថាបនិក ឬ ប្រធាន ។

## ជំពូកទី ៣
## ការធ្វើសម្ព័ន្ធភាព ការរំលាយ និង របាយការណ៍

**មាត្រា ១៥ :** សមាគមទាំងឡាយណា ដែលបានចុះបញ្ជីរួចហើយអាចធ្វើសម្ព័ន្ធភាពទ្វេភាគី ឬ ពហុភាគីជាមួយគ្នា បានដោយគ្រាន់តែជូនដំណឹងជាលាយល័ក្ខណ៍អក្សរដល់ក្រសួងមហាផ្ទៃ ។

**មាត្រា ១៦ :** ការរំលាយ សមាគម អាចប្រព្រឹត្តទៅបានក្នុងករណីណាមួយដូចខាងក្រោម :

-ការសំរេចរំលាយដោយខ្លួនឯង

-ការសំរេចរំលាយដោយរដ្ឋបាល

-ការសំរេចរំលាយដោយតុលាការ ។

១. ការរំលាយដោយខ្លួនឯង គឺការរំលាយសមាគមខ្លួនឯងដែលធ្វើឡើង តាមសេចក្តីសំរេចរបស់សន្និបាតដោយផ្អែកតាមសំណើរបស់ក្រុមប្រឹក្សាភិបាល និង អនុលោមតាមការកំណត់របស់លក្ខន្តិកៈ ។ សមាគម ដែលបានប្រកាសរំលាយដោយខ្លួនឯង ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ទៅក្រសួងមហាផ្ទៃ ។

២. ការរំលាយដោយរដ្ឋបាល គឺការផ្អាកសកម្មភាពសមាគម ដែលធ្វើឡើងដោយប្រកាសរបស់ក្រសួងមហាផ្ទៃ ក្នុងករណីដែលសមាគមបានប្រព្រឹត្តសកម្មភាពរំលោភច្បាប់ បណ្តាលឱ្យខូចសណ្តាប់ធ្នាប់សាធារណៈ ឬ សន្តិសុខជាតិ ឬ ប្រពៃណីល្អរបស់សង្គមខ្មែរ ឬ ប្រព្រឹត្តផ្ទុយនឹងលក្ខន្តិកៈ និង បទបញ្ជាផ្ទៃក្នុងរបស់សមាគម ។ ក្រសួងមហាផ្ទៃត្រូវបញ្ជូនសំណុំឯកសារភស្តុតាង អំពីអំពើខុសឆ្គងរបស់សមាគមទៅតុលាការ ។ ការរំលាយដោយរដ្ឋបាលនេះ សមាគម មានសិទ្ធិប្តឹងតវ៉ាទៅតុលាការក្នុងរយៈពេល ១៥ថ្ងៃ បន្ទាប់ពីថ្ងៃទទួលប្រកាស របស់ក្រសួងមហាផ្ទៃ ។ បើហួសរយៈពេលកំណត់នេះ ប្រកាសរបស់ក្រសួងមហាផ្ទៃត្រូវមាន ប្រសិទ្ធិភាពអនុវត្ត ។

៣. ការរំលាយដោយតុលាការ គឺធ្វើឡើងដោយសាលក្រម ឬ សាលដីកាស្ថាពរ របស់តុលាការក្នុងករណី ដែលសមាគមបានប្រព្រឹត្ត ឬ បញ្ជាឱ្យប្រព្រឹត្តជាក់ស្តែងនូវអំពើដែលទាក់ទងនឹងការ

វិលោភច្បាប់ធ្ងន់ធ្ងរ ឬ បទឧក្រិដ្ឋផ្សេងៗ ។ ការរំលាយដោយតុលាការនេះ ត្រូវចូលជាធរមាន បន្ទាប់ពីសមាគម បានប្រើប្រាស់សិទ្ធិប្ដឹងឧទ្ធរណ៍ចប់សព្វគ្រប់ ។

**មាត្រា ១៧ :** ទ្រព្យសម្បត្តិរបស់សមាគម ដែលត្រូវរំលាយ ត្រូវបានទទួលអាទិភាពចំពោះការសងបំណុល ស្របច្បាប់របស់សមាគមសាមី ។ ទ្រព្យសម្បត្តិរបស់សមាគម ដែលនៅសល់ត្រូវផ្ទេរទៅឱ្យសមាគមណាដែលបានចុះបញ្ជីរួចហើយ ស្របតាមការកំណត់ក្នុងលក្ខន្តិកៈ ឬ ការសំរេចរបស់សន្និបាត។ ក្នុងករណីរំលាយដោយតុលាការ ទ្រព្យសម្បត្តិដែលនៅសល់ ក្រោយពីការសងបំណុលស្របច្បាប់រួចហើយ ត្រូវតែសំរេចផ្ទេរទៅឱ្យកាកបាទក្រហមកម្ពុជា ។

**មាត្រា ១៨ :** សមាគមដែលបានចុះបញ្ជីរួចហើយ ត្រូវធ្វើរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួន ស្ដីពីសកម្មភាពសំខាន់ៗ តារាងតុល្យការ គណនីលទ្ធផល គណនីចំណូល ចំណាយ ព្រមទាំងឯកសារពាក់ព័ន្ធផ្សេងៗ ជូនក្រសួងមហាផ្ទៃ និងចតចម្លងជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យបានមុនថ្ងៃទី១៥ ខែធ្នូនៃឆ្នាំនីមួយៗ ។ សាធារណជនទាំងអស់មានសិទ្ធិទាក់ទងដោយផ្ទាល់នៅក្រសួងមហាផ្ទៃ ឬ ទីស្នាក់ការកណ្ដាលរបស់សមាគម ដើម្បីស្វែងយល់ពីរបាយការណ៍ ឬ លិខិតផ្សេងៗ ។

## ជំពូកទី ៤

## របបតតិយុត្តិ នៃ អង្គការក្រៅរដ្ឋាភិបាល

**មាត្រា ១៩ :** អង្គការក្រៅរដ្ឋាភិបាលត្រូវបំពេញលក្ខខ័ណ្ឌ តាមបទប្បញ្ញត្តិទាំងឡាយដូចមានចែងក្នុងជំពូកទី២ និងជំពូកទី ៣ នៃច្បាប់នេះ លើកលែងបដិប្បញ្ញត្តិ ។ អង្គការក្រៅរដ្ឋាភិបាលត្រូវស្ថិតក្រោមបទប្បញ្ញត្តិទាំងឡាយនៃជំពូកទី ៤ នៃច្បាប់នេះ ។

**មាត្រា ២០ :** អង្គការក្រៅរដ្ឋាភិបាល អាចអនុវត្តសកម្មភាពខាងសេវាណាមួយ នៅក្នុងវិស័យដូចជា ការបោះឆ្នោត សុខាភិបាល អប់រំ វប្បធម៌ សិល្បៈ បរិស្ថាន ជំនួយសង្គម ជំនួយអាជ្ញាធរសាធារណៈ ការពារសិទ្ធិមនុស្ស និង វិស័យផ្សេងៗទៀត ដែលបំរើប្រយោជន៍សាធារណៈ ។

**មាត្រា ២១ :** ធនធានសំរាប់អនុវត្តគំរោងកម្មវិធីរបស់អង្គការក្រៅរដ្ឋាភិបាល អាចមានប្រភពមកពីការផ្ដល់ធនធានក្រៅប្រទេស ។ នៅពេលធ្វើពាក្យសុំចុះបញ្ជីនៅក្រសួងមហាផ្ទៃ ត្រូវបញ្ជាក់ពីប្រភពដើម នៃមូលនីធិ និង ថវិកាប៉ាន់ស្មានសំរាប់អនុវត្តគំរោងកម្មវិធីនីមួយៗ ។ ក្នុងករណីមានការប្រែប្រួល ឬ មានគំរោងកម្មវិធីថ្មី ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រសួងមហាផ្ទៃ ។

**មាត្រា ២២ :** អង្គការក្រៅរដ្ឋាភិបាល ដែលបានចុះបញ្ជីរួចហើយ ត្រូវធ្វើរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួន ស្ដីពីសកម្មភាពសំខាន់ៗ អំពីការប្រើប្រាស់មូលនីធិដែលខ្លួនបានទទួល តារាងគំរោងផែនការ និង

សមិទ្ធិផលដែលខ្លួនសំរេចបាន តារាងតុល្យការ គណនីលទ្ធផល គណនីចំណូល ចំណាយ ព្រមទាំងឯកសារពាក់ព័ន្ធផ្សេងៗ ជូនក្រសួងមហាផ្ទៃ និង ចតចំលងជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឱ្យបានមុនថ្ងៃទី១៥ ខែធ្នូ នៃឆ្នាំនីមួយៗ ។ សាធារណៈជនទាំងអស់មានសិទ្ធិទាក់ទងដោយផ្ទាល់នៅក្រសួងមហាផ្ទៃ ឬ ទីស្នាក់ការកណ្តាល របស់អង្គការក្រៅរដ្ឋាភិបាលដើម្បីស្វែងយល់ពីរបាយការណ៍ ឬ លិខិតផ្សេងៗ ។

## ជំពូកទី ៥

## សិទ្ធិនិងផលប្រយោជន៍សមាគម និង អង្គការក្រៅរដ្ឋាភិបាល

**មាត្រា ២៣ :** គ្រប់វិភាគទានហិរញ្ញវត្ថុ ឬ អំណោយជាទេយ្យទាន ដែលបុគ្គល ឬ នីតិបុគ្គលណាមួយ បានផ្តល់ដល់សមាគម ឬ អង្គការក្រៅរដ្ឋាភិបាល ដែលបានចុះបញ្ជីរួចហើយ ត្រូវកាត់ចេញពីប្រាក់ចំណូលដើម ដែលត្រូវជាប់ពន្ធ មុនពេលគណនាពន្ធ ដែលត្រូវបង់លើប្រាក់ចំណូលដើមរបស់បុគ្គល ឬ នីតិបុគ្គលនោះ ។

**មាត្រា ២៤ :** ចំណូលជាហិរញ្ញវត្ថុ ឬ ជាសំភារៈប្រើប្រាស់ គ្រឿងបរិក្ខារ គ្រឿងចក្រ និង យានយន្ត ដែលសមាគម ឬ អង្គការក្រៅរដ្ឋាភិបាលបានទទួលពីបុគ្គល ឬ នីតិបុគ្គល ដើម្បីយកមកបំរើផលប្រយោជន៍សាធារណៈ ត្រូវបានអនុញ្ញាតិឱ្យនាំចូល ។ ពន្ធអាករលើការនាំចូលនោះជាបន្ទុករបស់រដ្ឋ។

**មាត្រា ២៥ :** ការកំណត់សារពើពន្ធផ្សេងៗទៀតរបស់សមាគម និង អង្គការក្រៅរដ្ឋាភិបាល ក្រៅពីចំណុចដូចមានចែងក្នុងមាត្រា ២៤ នៃច្បាប់នេះ ត្រូវអនុលោមតាមច្បាប់ និង បទប្បញ្ញត្តិនានាស្តីពីសារពើពន្ធនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២៦ :** សមាគម និង អង្គការក្រៅរដ្ឋាភិបាល ដែលបានចុះបញ្ជីរួចហើយ មានសិទ្ធិ :

ក. ធ្វើកិច្ចសន្យានានា

ខ. ជួលកម្មករ និង បុគ្គលិក

គ. បើកគណនីនៅធនាគារណាមួយ ដែលទទួលស្គាល់ដោយធនាគារជាតិ នៃកម្ពុជា ក្នុងនាមសមាគម ឬ អង្គការក្រៅរដ្ឋាភិបាល

ឃ. ត្រួតពិនិត្យ និង ធ្វើការសំរេចដោយខ្លួនឯង លើមុខចំណាយរបស់ខ្លួន

ង. រៀបចំប្រជុំតាមកាលកំណត់ និង ទីកន្លែងតាមការជ្រើសរើសរបស់ខ្លួន

ច. ផ្សព្វផ្សាយសកម្មភាពតាមមធ្យោបាយផ្សាយពត៌មានស្របច្បាប់នានា ។

## ជំពូកទី ៦

## ទោសប្បញ្ញត្តិ

**មាត្រា ២៧ :** ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចំនួន មួយរយពាន់រៀល (១០០.០០០ រៀល) ចំពោះសមាគម ឬ អង្គការក្រៅរដ្ឋាភិបាល ដែលមិនបានផ្តល់របាយការណ៍តាមការកំណត់ដូចមានចែង ក្នុងមាត្រា ១៨ ជំពូកទី ៣ និង មាត្រា ២២ ជំពូកទី ៤ នៃច្បាប់នេះ ។

ក្នុងរយពេល ៣០ថ្ងៃ បន្ទាប់ពីបានទទួលលិខិតជូនដំណឹង ស្តីពីការរំលឹកឱ្យផ្តល់របាយការណ៍របស់ក្រសួងមហាផ្ទៃ សមាគម ឬ អង្គការក្រៅរដ្ឋាភិបាលណា នៅតែមិនបានផ្តល់របាយការណ៍ទៀត ក្រសួងមហាផ្ទៃមានសិទ្ធិចេញប្រកាសផ្អាកជាបណ្តោះអាសន្ននូវសកម្មភាពសមាគម ឬ អង្គការក្រៅរដ្ឋាភិបាលនោះ ។

## ជំពូកទី ៧

## អន្តរប្បញ្ញត្តិ

**មាត្រា ២៨ :** បន្ទាប់ពីច្បាប់នេះចូលជាធរមាន សមាគម ឬ អង្គការក្រៅរដ្ឋាភិបាលទាំងអស់ ដែលកំពុងប្រតិបត្តិការក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវរៀបចំសំណុំលិខិតសុំចុះបញ្ជីតាមការកំណត់ដូចមានចែងក្នុងមាត្រា ៦ នៃច្បាប់នេះ ក្នុងរយៈពេលយ៉ាងយូរ ៩០ថ្ងៃ ។ បើហួសរយៈពេលដូចបានកំណត់ខាងលើ សមាគម ឬ អង្គការក្រៅរដ្ឋាភិបាលនោះ មិនត្រូវបានទទួលឋានៈជានីតិបុគ្គលឡើយ ។

## ជំពូកទី ៨

## អវសានប្បញ្ញត្តិ

**មាត្រា ២៩ :** បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣០ :** ច្បាប់នេះត្រូវប្រកាសជាប្រញាប់ ។